Australian Government
Department of Health and Aged Care

medicare

Khmer



# Medicare មាន អត្ថប្រយោជន៍ច្រើនទៀត

Medicare គឺជាប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសអូស្ត្រាលី ដែលផ្តល់ឱ្យប្រជាជនអូស្ត្រាលីទាំងអស់ទទួលបានសេវាសុខភាពដ៏ធំទូលាយក្នុងតម្លៃទាប ឬដោយមិនគិតថ្លៃ។

ចាប់ពីការទៅជួបវេជ្ជបណ្ឌិតពិនិត្យរោគទូទៅ (GP) ទៅការថែទាំនៅមន្ទីរពេទ្យ Medicare ធានាថាមនុស្សគ្រប់រូបអាចទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រដែលពួកគេត្រូវការ នៅពេលដែលពួកគេត្រូវការ។

## តើ Medicare មានន័យយ៉ាងណាដែរសម្រាប់អ្នក

Medicare កំពុងត្រូវបានពង្រឹងដើម្បីធ្វើឱ្យប្រាកដថា ប្រជាជនអូស្ត្រាលីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានការថែទាំសុខភាព ការថែទាំបន្ទាន់ និងសេវាសុខភាពផ្លូវចិត្តដែលមានតម្លៃសមរម្យ។

**Medicare មានន័យថា អ្នកអាចចូលប្រើ៖**

- សេវានានាដោយមិនគិតថ្លៃ ឬមានតម្លៃទាបជាង ពីវេជ្ជបណ្ឌិត និងអ្នកជំនាញសុខភាពផ្សេងទៀត
- ការថែទាំសុខភាពផ្លូវចិត្តដោយមិនគិតថ្លៃ ឬមានតម្លៃទាបជាង
- ការថែទាំបន្ទាន់ ដើរចូលដោយមិនគិតថ្លៃ តាមរយៈបណ្តាញដែលកំពុងរីកចម្រើននៃគ្លីនិកថែទាំបន្ទាន់ Medicare (Medicare Urgent Care Clinics)
- ការចំណាយមួយផ្នែក ឬទាំងអស់នៃសេវាសុខភាពមាត់ធ្មេញជាទូទៅមួយចំនួនសម្រាប់កុមារដែលមានសិទ្ធិទទួល ក្រោមគម្រោងអត្ថប្រយោជន៍ថែទាំសុខភាពមាត់ធ្មេញសម្រាប់កុមារ។

មានអត្ថប្រយោជន៍ Medicare ជាច្រើនទៀតផងដែរ។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ Services Australia (សេវាកម្មអូស្ត្រាលី)។

## ទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី Medicare

នេះជារបៀបដែលអ្នកអាចទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី Medicare៖:

- **ចុះឈ្មោះក្នុង Medicare៖**
  - ចុះឈ្មោះតាមអនឡាញតាមរយៈ myGov
  - បំពេញទម្រង់បែបបទចុះឈ្មោះ Medicare ហើយដាក់ស្នើទម្រង់បែបបទ និងឯកសារគាំទ្ររបស់អ្នកតាមប្រៃសណីយ៍ ឬអ៊ីមែល ឬ
  - អញ្ជើញទៅកាន់មជ្ឈមណ្ឌលសេវាកម្ម Services Australia។
- **ចូលប្រើការថែទាំនៅពេលណា និងកន្លែងណាដែលអ្នកត្រូវការវា៖**
  - **GP អ្នកឯកទេស និង ការណាត់ជួបសុខភាពតាមទូរសព្ទ៖** ពិនិត្យមើលថាតើអ្នកផ្តល់សេវារបស់អ្នក ផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋឬអត់។ ប្រសិនបើពួកគេមិនផ្តល់ជូនទេ អ្នកនឹងត្រូវបង់ថ្លៃសេវា ហើយបន្ទាប់មកធ្វើការទាមទារពី Medicare។ អ្នកក៏អាចសួរថាតើ GP ឬអ្នកឯកទេសរបស់អ្នកផ្តល់ជូនការប្រឹក្សាតាមទូរសព្ទ ឬវីដេអូ ឬអត់សម្រាប់ភាពងាយស្រួល ប្រសិនបើអ្នកមានសិទ្ធិទទួល។
  - អញ្ជើញទៅកាន់**គ្លីនិកថែទាំបន្ទាន់ Medicare៖** ចូលប្រើការថែទាំ ដើរចូលដោយមិនគិតថ្លៃ សម្រាប់ការថែទាំបន្ទាន់ ប៉ុន្តែមិនគំរាមកំហែងដល់អាយុជីវិត។
- **ចូលប្រើការគាំទ្រសម្រាប់សុខុមាលភាពរបស់អ្នក៖**
  - អញ្ជើញទៅកាន់**មជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត Medicare៖** ការគាំទ្រ ដើរចូលដោយមិនគិតថ្លៃ អាចរកបានសម្រាប់សុខភាពផ្លូវចិត្ត និងសុខុមាលភាពនៅទូទាំងប្រទេសអូស្ត្រាលី។
- **ចូលប្រើការគាំទ្រសុខភាពមាត់ធ្មេញសម្រាប់កុមារ៖**
  - កុមារដែលមានសិទ្ធិទទួល អាចចូលប្រើគម្រោងអត្ថប្រយោជន៍ថែទាំសុខភាពមាត់ធ្មេញសម្រាប់កុមារ ដើម្បីគ្របដណ្តប់ថ្លៃចំណាយមួយផ្នែក ឬទាំងអស់នៃសេវាសុខភាពមាត់ធ្មេញជាទូទៅ។



## តើអ្នកណាអាចចូលប្រើ Medicare?

អ្នកមានសិទ្ធិទទួលបាន Medicare ប្រសិនបើអ្នករស់នៅក្នុងប្រទេសអូស្ត្រាលី ហើយអ្នក៖

- ជាពលរដ្ឋអូស្ត្រាលី ឬនូវែលសេឡង់
- ជាអ្នកស្នាក់នៅក្នុងប្រទេសអូស្ត្រាលីអចិន្ត្រៃយ៍
- កំពុងដាក់ពាក្យសុំស្នាក់នៅអចិន្ត្រៃយ៍ (លក្ខខណ្ឌនានាត្រូវអនុវត្ត)
- ជាអ្នកស្នាក់នៅបណ្តោះអាសន្នដែលគ្របដណ្តប់ដោយបទបញ្ជារបស់ក្រសួង
- ជាពលរដ្ឋ ឬអ្នករស់នៅអចិន្ត្រៃយ៍នៃកោះ Norfolk, កោះ Cocos (Keeling), កោះគ្រីស្ទម៉ាស (Christmas) ឬកោះ Lord Howe។

អ្នកក៏មានសិទ្ធិទទួលបាន Medicare ដែរ ប្រសិនបើអ្នកកំពុងទស្សនាប្រទេសអូស្ត្រាលីពីប្រទេសដែលមានកិច្ចព្រមព្រៀងថែទាំសុខភាពទៅវិញទៅមក (លក្ខខណ្ឌនានាត្រូវអនុវត្ត)។

## ការយល់ដឹងអំពីអត្ថប្រយោជន៍ Medicare

អត្ថប្រយោជន៍នានាដែលអ្នកទទួលបានពី Medicare គឺផ្អែកលើបញ្ជីថ្លៃសេវាកំណត់ដោយរដ្ឋាភិបាលអូស្ត្រាលី ដែលហៅថា តារាងអត្ថប្រយោជន៍វេជ្ជសាស្ត្រ (MBS)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក អាចជ្រើសរើសគិតថ្លៃសេវាច្រើនជាងថ្លៃសេវា MBS។

**អត្ថប្រយោជន៍ Medicare** គឺជាចំនួនទឹកប្រាក់ដែលអ្នកទទួលបានមកវិញពី Medicare នៅពេលអ្នក**ទាមទារ**សម្រាប់ថ្លៃសេវាវេជ្ជសាស្ត្រ។

មធ្យោបាយលឿនបំផុតដើម្បីទាមទារអត្ថប្រយោជន៍ Medicare របស់អ្នក គឺនៅការិយាល័យវេជ្ជបណ្ឌិតរបស់អ្នកភ្លាមៗបន្ទាប់ពីអ្នកបង់ប្រាក់។

- ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នក**គិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ** វាមានន័យថា Medicare គ្របដណ្តប់ថ្លៃសេវាដែលអ្នកបានទទួល ហើយអ្នកមិនបង់ប្រាក់អ្វីទាំងអស់។
- ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកមិនផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋទេ អ្នកនៅតែអាចធ្វើការ**ទាមទារពី Medicare** បន្ទាប់ពីអ្នកបង់ថ្លៃសេវាពេញ។ ប្រសិនបើអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកគិតថ្លៃច្រើនជាងអ្វីដែល Medicare គ្របដណ្តប់ នោះអ្នកនឹងចាំបាច់ត្រូវបង់ថ្លៃចំណាយ**ពីហោប៉ៅ**។

## ព័ត៌មានបន្ថែម

**ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែល Medicare អាចជួយអ្នក សូមចូលទៅកាន់គេហទំព័រ medicare.gov.au/stronger**

ស្កេនដើម្បីស្វែងយល់បន្ថែម